

## គ្រោះថ្នាក់អគ្គីភ័យដោយសារគ្រឿងម៉ាស៊ីន និងគ្រឿងឧបករណ៍

១. កុំបញ្ឆេះឬបើកបរយានយន្ត (ក្នុងវង្វង់អត្ថន័យច្បាប់យានយន្ត) ឬបញ្ឆេះគ្រឿងម៉ាស៊ីន បើពុំមានដាក់ឧបករណ៍បំបាត់ផ្កាភ្លើងទេនោះ។

២. កុំប្រើគ្រឿងឧបករណ៍អេឡិកត្រូនិកឬឧស្ម័នសំរាប់ផ្សាឬកាត់ នៅទីចំហនៅក្នុងតំបន់ការពារមិនឲ្យមានភ្លើងឆេះ ឬក្នុងអម្លុងពេលគ្រោះថ្នាក់ភ្លើងឆេះ ឬថ្ងៃហាមឃាត់ដុតភ្លើង:

ក) ក្នុងរង្វង់ចម្ងាយ ៤ ម៉ែត្រពីវត្ថុណាមួយដែលអាចឆេះបាន; និង

ខ) លើកលែងតែមានឧបករណ៍លត់ភ្លើងរួចជាស្រេច

## មិនត្រូវបោះចោលវត្ថុដែលឆេះឡើយ

ត្រូវពន្លត់ឲ្យបានពេញលេញនូវបារីនិងវត្ថុដែលឆេះឬឆេះតិចៗផ្សេងទៀត មុនពេលបោះវាចោល។

**ពិន័យ:** $៥000 ឬជាប់ពន្ធនាគារ ៥ ឆ្នាំ។

## ឧបសគ្គ

ការបង្កឧបសគ្គដល់ Fire Warden ឬ Fire Control Officer (ភ្នាក់ងារគ្រប់គ្រងអគ្គីភ័យ) នៅក្នុងការអនុវត្តភារកិច្ចរបស់គេ ឬការមិនធ្វើតាមតម្រូវការណាមួយ គឺជាអំពើល្មើសមួយ។

**ពិន័យ:** $៥000 ឬជាប់ពន្ធនាគារ ២ ឆ្នាំ។

ការផ្តល់ព័ត៌មានក្លែងក្លាយ ឬផ្តល់ឯកសារក្លែងក្លាយទៅឲ្យ Fire Warden ឬ Fire Control Officer ដែលអនុវត្តភារកិច្ចរបស់គេ គឺជាអំពើល្មើសមួយ។

**ពិន័យ:** $៥000 ឬជាប់ពន្ធនាគារ ២ ឆ្នាំ។

នេះមិនមែនជាឯកសារច្បាប់ទេ ប៉ុន្តែគ្រាន់តែជាសេចក្តីសង្ខេបនៃ**ច្បាប់ភ្លើងឆេះព្រៃគុម្ពោត**ប៉ុណ្ណោះ។ ឯកសារនេះមិនប្រាប់អំពី“ខ”ទាំងអស់នៃច្បាប់ឡើយ ប៉ុន្តែឃោងទៅកាន់បញ្ហាដែលនឹងជាការបារម្ភរបស់ប្រជាពលរដ្ឋភាគច្រើន។

## ដើម្បីទទួលព័ត៌មានបន្ថែម សូមទាក់ទង


**DARWIN HEADQUARTERS**
1718 Albatross Street Winnellie
PO Box 37346 Winnellie NT 0821
ទូរស័ព្ទ: 8922 0844
ទូរសារ: 8922 0833
www.nt.gov.au/bushfires

**BATCHELOROFFICE**
142 Cameron Road Batchelor
c/o Post Office Batchelor NT 0845
ទូរស័ព្ទ: 8976 0098 ឬ 8976 0321
ទូរសារ: 8976 0222

**KATHERINE OFFICE**
32 Giles Street Katherine
PO Box 532 Katherine NT 0851
ទូរស័ព្ទ: 8973 8888
ទូរសារ: 8973 8899

**TENNANT CREEK OFFICE**
2 Leichardt Street Tennant Creek
PO Box 846 Tennant Creek NT 0861
ទូរស័ព្ទ: 8962 4522 ឬ 8962 4577
ទូរសារ: 8962 2651

**ALICE SPRINGS OFFICE**
3 Elder Street Alice Springs
PO Box 2533 Alice Springs NT 0871
ទូរស័ព្ទ: 8952 3066
ទូរសារ: 8952 7576




# ច្បាប់គោលការណ៍អគ្គីភ័យរបស់

## Northern Territory

*ច្បាប់ភ្លើងឆេះព្រៃគុម្ពោត ត្រូវបានបង្កើតឡើងដើម្បីជួយការពារជីវិត ដីធ្លីទព្យសម្បត្តិ និងបរិស្ថាន តទល់នឹងការគំរាមកំហែងនៃភ្លើងឆេះព្រៃ។ ច្បាប់នេះមានមាត្រាសំខាន់មួយចំនួនដែលតម្រូវឲ្យម្ចាស់ដីអនុវត្តតាម។*


Northern Territory Government
Department of Natural Resources, Environment and the Arts

BUSHFIRES NT



## ច្បាប់ភ្លើងឆេះព្រៃគុម្ពោត

ច្បាប់ចែងថា លោកអ្នកមិនត្រូវដុតភ្លើង ឬបង្កឲ្យមានភ្លើងឆេះដីធ្លីឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ជនណាមួយផ្សេងទៀតឡើយ ដែលនៅក្នុងកាលៈទេសៈដូចនោះ នឹងបង្កឬទំនងជាបង្កការខូចខាតដល់ជនដទៃទៀតនោះ ឬដីធ្លី ឬទ្រព្យសម្បត្តិនោះ។

**ពិន័យសំរាប់ការមិនធ្វើតាមច្បាប់ភ្លើងឆេះព្រៃគុម្ពោតៈ**

ចំនួនប្រាក់ $២៥០០០ ឬជាប់ពន្ធនាគារ ៥ ឆ្នាំ។

## តំបន់ការពារមិនឲ្យមានភ្លើងឆេះ

នៅក្នុង Northern Territory តំបន់មួយចំនួនត្រូវបានគេប្រកាសថា ជាតំបន់ការពារមិនឲ្យមានភ្លើងឆេះ។ តំបន់ទាំងនោះមានដូចតទៅៈ

- កាំចម្ងាយ 50 គីឡូម៉ែត្រ ពី Katherine PO
- កាំចម្ងាយ 50 គីឡូម៉ែត្រ ពី Tennant Creek PO
- កាំចម្ងាយ 50 គីឡូម៉ែត្រ ពីអាកាសយានដ្ឋាន Alice Springs
- តំបន់ការពារអគ្គីភ័យនៅខាងជើង ដូចនៅក្នុងផែនទី។




លោកអ្នកមិនត្រូវដុតគុម្ពោតព្រៃ ឬវត្ថុអាចឆាបឆេះផ្សេងទៀតណាមួយឡើយ ក្នុងរង្វង់តំបន់ការពារមិនឲ្យមានភ្លើងឆេះនៅគ្រប់ពេលទាំងអស់ លើកលែងតែនិងសមស្របទៅតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាតឲ្យដុតដែលចេញដោយ Fire Warden ឬ Fire Control Officer ។

បើលោកអ្នកចាំបាច់ត្រូវប្រើភ្លើងសំរាប់គោលបំណងបោះជំរំ ចំអិនអាហារ ឬដុតចោលខ្មោចសត្វយ៉ាងរហ័ស លោកអ្នកមិនត្រូវដុតភ្លើងឡើយ លើកលែងតែៈ

ក) វត្ថុអាចឆាបឆេះបានដែលនៅជិតភ្លើងបំផុត មានចម្ងាយលើសពី ៤ ម៉ែត្រឡើងទៅ

ខ) ភ្លើងត្រូវបានពន្លត់យ៉ាងពេញលេញ មុនពេលចាកចេញទៅ។



## ការដុតនៅក្រៅតំបន់ការពារមិនឲ្យមានភ្លើងឆេះ – តំបន់គ្រោះថ្នាក់ភ្លើងឆេះ

លោកអ្នកអាចដុតភ្លើងបានដោយពុំចាំបាច់មានការអនុញ្ញាត នៅលើដីធ្លី នៅក្រៅតំបន់ការពារមិនឲ្យមានភ្លើងឆេះ លើកលែងតែដីធ្លីនោះស្ថិតនៅក្នុងរង្វង់តំបន់ដែលគេប្រកាសថាជាតំបន់គ្រោះថ្នាក់ភ្លើងឆេះ។

ក្នុងអម្លុងរដូវអគ្គីភ័យ រដ្ឋមន្ត្រីអាចប្រកាសឲ្យមានរយៈពេលគ្រោះថ្នាក់ភ្លើងឆេះនៅតាមតំបន់មួយចំនួនដែលកំណត់ដោយខ្សែរយៈទទឹង។ នៅពេលដែលមានការប្រកាសនូវរយៈពេលមួយដូចនោះ ការរឹតត្បិតដូចតទៅនេះត្រូវអនុវត្តចំពោះការបង្កាត់ភ្លើងទាំងអស់នៅនឹងទីចំហ។

បើត្រូវការភ្លើងសំរាប់គោលបំណងឆ្ការសំអាតដី ប្រមូលផ្តុំសត្វពាហនៈ ដុតសំរាប់បង្កើតច្រកផ្លូវកុំឲ្យភ្លើងឆេះរាលដាល ឬសំរាប់គោលបំណងផ្សេងទៀត លោកអ្នកត្រូវទទួលការអនុញ្ញាតឲ្យដុតជាមុនសិន ពី Fire Warden ឬ Fire Control Officer ហើយត្រូវអនុវត្តតាមលក្ខខណ្ឌដូចតទៅនេះៈ

ក) ត្រូវផ្តល់សេចក្តីជូនដំណឹងយ៉ាងតិច ៤៨ ម៉ោងជាមុន ទៅឲ្យអ្នកជិតខាងទាំងអស់ដែលនៅជាប់នឹងដីធ្លីដែលមានគោលបំណងដុតភ្លើង

ខ) គួរដុតភ្លើងនៅពេលដែលមានអាកាសធាតុអំណោយផលតែប៉ុណ្ណោះ

គ) ត្រូវមានកម្លាំងមនុស្សនិងគ្រឿងឧបករណ៍គ្រប់គ្រាន់ជាស្រេច នៅគ្រប់ពេលទាំងអស់ដើម្បីគ្រប់គ្រងភ្លើងឆេះ។

**បំរាមភ្លើងឆេះ**

បំរាមលើការបង្កាត់ភ្លើងនៅទីចំហអាចត្រូវបានអនុវត្ត ក្នុងអម្លុងពេលមានគ្រោះថ្នាក់ភ្លើងឆេះខ្លាំងណាស់ ឬខ្លាំងមែនទែន។ ក្នុងអម្លុងពេលនេះ គេ**មិនត្រូវដុតភ្លើង**ប្រភេទណាមួយនៅក្នុងទីចំហឡើយ លើកលែងតែត្រូវប្រើភ្លើងទាំងនេះសំរាប់ចំអិនអាហារឬដាំទឹក ឲ្យតែវត្ថុអាចឆាបឆេះបានដែលនៅជិតភ្លើងបំផុត មានចម្ងាយលើសពី ៤ ម៉ែត្រឡើងទៅ។

បំរាមភ្លើងឆេះត្រូវបានប្រកាសតាមវិទ្យុនិងសារព័ត៌មាន។ នៅពេលដែលគេដកបំរាមនេះចេញ ការរឹតត្បិតធម្មតាលើការដុត នៅតែអនុវត្តតទៅទៀត។ បើលោកអ្នកមានភ្លើងឆេះនៅក្នុងបរិវេណដីធ្លីរបស់លោកអ្នក ដែលបានឆេះមុនពេលចាប់ផ្តើមបំរាមភ្លើងឆេះ  លោកអ្នកត្រូវពន្លត់ភ្លើងនេះ ឬមួយបើលោកអ្នកមិនអាចពន្លត់ភ្លើងនេះបានទេ លោកអ្នកត្រូវប្រាប់ Fire Warden ឬ Fire Control Officer ដោយមិនអែរអង់ឡើយ។

**ពិន័យៈ** $២៥០០០ ឬជាប់ពន្ធនាគារ ៥ ឆ្នាំ។



## អំណាចរបស់ FIRE CONTROL OFFICER និង FIRE WARDEN

នៅក្រោមច្បាប់ភ្លើងឆេះគុម្ពោតព្រៃ សំរាប់គោលបំណងគ្រប់គ្រងភ្លើងឆេះគុម្ពោតព្រៃ ឬការពារទ្រព្យសម្បត្តិ ឬជីវិតដោយសារគ្រោះថ្នាក់បណ្តាលដោយភ្លើងឆេះគុម្ពោតព្រៃ  Fire Control Officer ឬ Fire Warden មានអំណាចដើម្បីៈ

ក) ចូលទៅក្នុងអគារ ឬដីធ្លីណាមួយ

ខ) ផ្តួលរំលំ កាត់ចេញ ឬដករបងណាមួយចេញ

គ) បង្កើតច្រកផ្លូវរារាំងកុំឲ្យភ្លើងឆេះរាលដាល ដោយប្រើភ្លើងដុត

ឃ) យកទឹកចេញពីប្រភពណាមួយ ក្រៅពីទឹកសំរាប់បរិភោគ ឬទឹកប្រើប្រាស់តាមផ្ទះ

ង) បិទផ្លូវឬកន្លែងសាធារណៈណាមួយ មិនឲ្យមានចរាចរណ៍ចេញចូល

ច) តម្រូវឲ្យជនណាមួយដែលគេសង្ស័យដោយសមហេតុផលថា បានធ្វើអំពើល្មើសនឹងច្បាប់ ឲ្យផ្តល់ឈ្មោះពេញ និងកន្លែងរស់នៅ ព្រមទាំងបង្ហាញលិខិតអនុញ្ញាតណាមួយដែលជននោះមាន។

ឆ) តម្រូវឲ្យជនណាមួយដែលបានដុតឬកំពុងប្រើភ្លើងផ្ទុយនឹងច្បាប់ ពន្លត់ភ្លើងនោះជាបន្ទាន់។

## ការបង្ការកុំឲ្យមានភ្លើងឆេះ

Chief Fire Control Officer (ប្រធានគ្រប់គ្រងអគ្គីភ័យ) អាចតម្រូវឲ្យលោកអ្នកធ្វើច្រកផ្លូវរារាំងភ្លើងឆេះរាលដាលនៅលើដីធ្លី ឬដកវត្ថុអាចឆេះបានចេញពីដីធ្លី ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកអ្នក។

**ពិន័យៈ** $៥០០០ ឬជាប់ពន្ធនាគារ ២ ឆ្នាំ និង $៥០០ សំរាប់ថ្ងៃនីមួយៗដែលអំពើល្មើសនោះកើតមានតទៅទៀត។

## ម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ដីធ្លី

បើលោកអ្នកជាម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ដីធ្លីណាមួយ ហើយគេបានប្រាប់ ថាភ្លើងឆេះនៅលើដីលោកអ្នកទំនងជាឆេះរាលដាលទៅកាន់ដីឯទៀត លោកអ្នកត្រូវចាប់យកជំហានសមហេតុផលទាំងឡាយដើម្បីគ្រប់គ្រងភ្លើងឆេះនោះ។ បើលោកអ្នកមិនអាចធ្វើយ៉ាងនេះបានទេ លោកអ្នកត្រូវប្រាប់ភ្លាមទៅកាន់ៈ

ក) Fire Warden ឬ Fire Control Officer និង

ខ) អ្នកកាន់កាប់ដីធ្លីជិតខាងទាំងអស់ អំពីហេតុការណ៍នោះ។

**ពិន័យៈ** $៥០០០ ឬជាប់ពន្ធនាគារ ២ ឆ្នាំ។